# រាជរដ្ឋាភិបាលកម្ពុជា

## ក្រសួងផែនការ

### វេទិកាទី១ : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) បច្ចុប្បន្នកម្ម ២០០៩-២០១៣

**បង្ហាញដោយ : ឯកឧត្តម ឆាយ ថន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**

**នៅក្នុង វេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា លើកទី៣**

**រាជធានីភ្នំពេញ ថ្ងៃទី ២-៣ ខែមិថុនា ឆ្នាំ២០១០**

១. នៅក្នុងវេទិកាដ៏សំខាន់នេះ ខ្ញុំមានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី និង អង្គវេទិកាទាំងមូលជ្រាបថា *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) បច្ចុប្បន្នកម្ម ២០០៩-៣០១៣* ត្រូវបានអនុម័តរដ្ឋសភារួចហើយ កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១០ ហើយរង់ចាំការអនុម័តពីព្រឹទ្ធសភា និងការឡាយព្រះហស្តលេខាពីព្រះមហាក្សត្រលើព្រះរាជក្រម ដើម្បីប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ ។ បន្ទាប់ពីនេះ ឯកសារ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* នឹងត្រូវបានធ្វើការផ្សព្វផ្សាយជាផ្លូវការ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងពិធីផ្សព្វផ្សាយជាតិមួយ ហើយនឹងត្រូវបានបែងចែកយ៉ាងទូលំទូលាយ ដល់ស្ថាប័នទាំងអស់របស់រាជរដ្ឋាភិបាល នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ រួមទាំងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផងដែរ ។ យោងទៅតាមរបៀបវារៈរបស់វេទិកានាថ្ងៃនេះ ខ្ញុំសូមធ្វើការបង្ហាញជូនអង្គវេទិកាទាំងមូលជ្រាប ពីវឌ្ឍនភាពដែលរាជរដ្ឋាភិបាលកម្ពុជាបានអនុវត្ត *ផយអជ ២០០៦-២០១០* រួមទាំង*គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (គអសក)* ដំណើរការនៃការរៀបចំ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* និងកាលានុវត្តភាពនិងបញ្ហាប្រឈមនានា ដែលទាមទារឱ្យមានការដោះស្រាយ នៅក្នុងដំណាក់កាលនៃ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ។

២. មុននឹងចាប់ផ្តើមបទបង្ហាញ ខ្ញុំសូមរំលឹកជូនអង្គវេទិកាទាំងមូលឱ្យបានជ្រាបថា ទើបតែចាប់ពីឆ្នាំ១៩៩៩មកប៉ុណ្ណោះ (គឺប្រមាណជាងមួយទសវត្សរ៍កន្លងទៅ) ដែលប្រជាជនកម្ពុជាបានរស់នៅដោយទទួលបានយ៉ាងពេញលេញ នូវបរិយាកាសមួយដែលមាន សន្តិភាព ស្ថិរភាពនយោបាយ ច្បាប់និង សណ្តាប់ធ្នាប់សង្គម លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និង ស្ថិរភាពសេដ្ឋកិច្ច ។ ខ្ញុំមានមោទនភាពនឹង លើកឡើងថា ក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ យើងបានធ្វើឱ្យមានវឌ្ឍនភាពដ៏ធំធេង ក្នុងការដឹកនាំប្រទេសជាតិ ឱ្យបោះជំហានទៅមុខ ក្នុងគន្លងផ្លូវ សន្តិភាព ស្ថិរភាព កំណើនសេដ្ឋកិច្ចខ្ពស់ និងការកាត់បន្ថយភាពក្រីក្រ ។

៣. ជារួម ទោះបីជាមានបញ្ហាប្រឈមថ្មីៗ ដែលបានលេចចេញ ដោយមិនបានរំពឹងទុកជាមុន ក្នុងរូបភាពជាបច្ច័យអាក្រក់មួយ នៃវិបត្តិសេដ្ឋកិច្ចសកលលោក និងកលិយុគនៅក្នុងទីផ្សារហិរញ្ញវត្ថុសកលលោក ដែលបណ្តាល

មកពីបរាជ័យនៃប្រព័ន្ធគ្រប់គ្រងទីផ្សារ នៅក្នុងសេដ្ឋកិច្ចរីកចម្រើនមួយចំនួនក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជាបានពង្រឹងបន្ថែមទៀត នូវសមិទ្ធផលទាំងឡាយរបស់ខ្លួន ដោយបន្តការអនុវត្តប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ នូវ*យុទ្ធសាស្ត្រចតុកោណ* តាមរយៈ *ផយអជ ២០០៦-២០១០* ។ សមិទ្ធផលសំខាន់ៗ ដ៏គួរឱ្យកត់សម្គាល់ រួមមាន :

- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និង សណ្តាប់ធ្នាប់សង្គម ត្រូវបានពង្រឹង នៅលើមូលដ្ឋាននៃលទ្ធិ-ប្រជាធិបតេយ្យសេរីពហុបក្ស ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់លើកទីពីរដោយសេរី និងយុត្តិធម៌ ត្រូវបានរៀបចំឡើងក្នុងឆ្នាំ២០០៧ ។ ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រលើកទី៤ ត្រូវបានរៀបចំឡើង ក្នុងខែកក្កដា ឆ្នាំ២០០៨ ។
- ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងកម្រិតពីរខ្ទង់ ដែលមិនធ្លាប់មានពីមុនមក ត្រូវបានធានាឱ្យមាន ព្រមគ្នានឹង ការរក្សាអតិផរណាឱ្យមានកម្រិតទាបនិងអត្រាប្តូរប្រាក់ឱ្យមានស្ថិរភាព ។ ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិត្រូវបានពង្រឹង តាមរយៈ ការបង្កើនផលិតភាពកសិកម្ម ការកសាងមូលដ្ឋានសេដ្ឋកិច្ចជនបទ ការពង្រីកវិស័យឧស្សាហកម្ម ជាពិសេស ដើម្បីពង្រីកបន្ថែមទៀតនូវជវភាពនៃវិស័យឧស្សាហកម្មកាត់ដេរ ។ វិស័យសេវាកម្មទាំងមូល ក៏ត្រូវបានពង្រីកយ៉ាងឆាប់រហ័ស ផងដែរ ។ ប្រការទាំងអស់នេះបានបង្កើត ការងារនិងការបណ្តុះបណ្តាលមុខជំនាញជាច្រើន ដល់យុវជននិងយុវនារីជាច្រើនសែននាក់ ។
- តាមរយៈ *"កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ"* ភាពអាចជឿទុកចិត្តបាននៃថវិកា ត្រូវបានបង្កើន ដូចដែលបានសម្តែងឱ្យឃើញ តាមរយៈ ការបង្កើនចំណូល និងការធ្វើវិចារណកម្មចំណាយរបស់រាជរដ្ឋាភិបាល ជាពិសេស ការបង្កើនអតិរេកចរន្តនៃថវិកាជាតិ ដែលបានរួមចំណែកក្នុងការពង្រីក ការវិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចនិងសង្គមកិច្ច សំដៅការលើកកម្ពស់សេវាកម្មសាធារណៈ និងការកាត់បន្ថយភាពក្រីក្រ ។
- តាមរយៈ ការអនុវត្តប្រកបដោយជោគជ័យនូវ គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា យើងមានលទ្ធភាពកាត់បន្ថយកម្រិតនៃភាពក្រីក្របានគួរឱ្យកត់សម្គាល់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។
- វិស័យសង្គមកិច្ច បាននិងកំពុងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ : នៅក្នុងវិស័យអប់រំ អត្រានៃការសិក្សាបានកើនឡើង ហើយអត្រាបោះបង់ចោលការសិក្សានិងអត្រាត្រួតថ្នាក់ បានធ្លាក់ចុះ ចំណែកឯនៅក្នុងវិស័យសុខាភិបាល អត្រាមរណភាពទារកនិងកុមារ និងអត្រាអ្នកផ្ទុក មេរោគអេដស៍/ជំងឺអេដស៍ ក៏បានធ្លាក់ចុះផងដែរ ។
- វិស័យឯកជនបានក្លាយទៅជា "ក្បាលម៉ាស៊ីនពិតប្រាកដនៃកំណើនសេដ្ឋកិច្ច" ហើយបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ទាំងក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត និងទាំងក្នុងវិស័យហិរញ្ញវត្ថុ ។
- ភាពជាដៃគូជាមួយអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ ជាពិសេស ជាមួយដៃគូអភិវឌ្ឍន៍ផ្លូវការ វិស័យឯកជន និងសង្គមស៊ីវិល ត្រូវបានពង្រឹង ។

៤.	ចំពោះភាពក្រីក្រ យើងកាត់បន្ថយក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់ ។ នៅក្នុងសុន្ទរកថាដែលបាន ចែកជូន មានបញ្ជាក់លម្អិតពីភាពជោគជ័យនេះ ។ ខ្ញុំសូមលើកឡើង ពីចំណុចសំខាន់ៗមួយចំនួន ដូចខាងក្រោម :

- នៅក្នុងអំឡុងពេល ពីឆ្នាំ២០០៤ ដល់ ឆ្នាំ២០០៧ កម្រិតនៃភាពក្រីក្រ បានថយចុះ ៤,៦ភាគរយ ដោយបង្ហាញឱ្យឃើញពីការថយចុះ ក្នុងកម្រិតច្រើនជាង ១ភាគរយ ក្នុងមួយឆ្នាំ ។
- ការកើនគួរឱ្យកត់សម្គាល់ ទាំងផ្នែកបរិមាណនិងគុណភាព នៃការប្រើប្រាស់ពិតតាមគ្រួសារសម្រាប់មនុស្សម្នាក់ៗ (ដែលត្រូវបានគេប្រើប្រាស់ជាទូទៅសម្រាប់វាស់វែងស្តង់ដារនៃការរស់នៅ) ត្រូវបានធ្វើឱ្យកើតមានឡើង ។
- ភាពប្រសើរឡើងគួរឱ្យកត់សម្គាល់នៃសុខុមាលភាព ក្នុងក្រុមបញ្ចភាគដែលក្រីក្របំផុត និងក្រុមបញ្ចភាគដែលក្រីក្របំផុតបន្ទាប់ ត្រូវបានធ្វើឱ្យសម្រេចបាន ដោយសារតែ ការធ្វើឱ្យប្រសើរឡើងនៃកត្តាជាច្រើនដែលពាក់ព័ន្ធនឹងការផ្តល់សេវាកម្ម និងលទ្ធផលនានានៃការអភិវឌ្ឍមនុស្ស ។ សមិទ្ធផលជាច្រើន ត្រូវបានសង្កេតឃើញមាន នៅក្នុងវិស័យ អប់រំ សុខាភិបាល ផលិតកម្មកសិកម្ម និង អាហារូបត្ថម្ភ ។ ការទទួលបានជារូបវន្តនូវសេវាកម្មសាធារណៈផ្សេងៗ ត្រូវបានធ្វើឱ្យប្រសើរឡើង ដោយគិតជា ចម្ងាយមធ្យមទៅកាន់មណ្ឌលសុខភាពឬសាលារៀន ដែលនៅជិតបំផុត ។ ប្រការទាំងនេះ ក៏បានរួមផ្សំផងដែរ ជាមួយនឹងការលើកកម្ពស់ទាំងបរិមាណនិងគុណភាពនៃបណ្តាញផ្លូវថ្នល់ និងការកើនឡើងនៃប្រាក់ចំណូលពិត បង្ហាញឱ្យឃើញពីមូលហេតុនៃការធ្វើឱ្យប្រសើរឡើងនូវ អត្រានៃការសិក្សា ឬ ឥរិយាបថនៃការគិតគូរដល់សុខភាព ។ ជាមួយគ្នានេះ លទ្ធផលការងារជាច្រើន ត្រូវបានបន្តធ្វើឱ្យប្រសើរឡើង ដូចជា កម្រិតមធ្យមនៃការទទួលបានការអប់រំ និងស្ថានភាពសុខភាពដែលត្រូវបានរាយការណ៍ ដោយសាមីខ្លួនផ្ទាល់ ។

៥.	ការការពារសមិទ្ធផលដែលសម្រេចបានដោយលំបាក និងការប្រកាន់យកនូវមាគ៌ាដែលត្រូវធានានូវជោគជ័យនាពេលអនាគតក្នុងការកាត់បន្ថយភាពក្រីក្រ ឥឡូវនេះ បានបន្ថែមនូវបញ្ហាប្រឈមជាច្រើនថែមទៀត ដោយសារវិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចសកលលោក ។

៦.	ដោយមានគោលបំណងធ្វើឱ្យមានវឌ្ឍនភាព ឆ្ពោះទៅសម្រេច *គោលដៅអភិវឌ្ឍសហស្សវត្សរ៍កម្ពុជា (គអសក)* យើងបានឯកភាពចំពោះគោលដៅចំនួន ៩ នៅឆ្នាំ២០០៣ ដែលរួមបញ្ចូលទាំង គោលដៅទី៩ ទាក់ទងនឹង ការដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះ ។ បច្ចុប្បន្ន ក្រសួងផែនការ ដោយមានការគាំទ្រពី កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅកម្ពុជា កំពុងដំណើរការរៀបចំ *របាយការណ៍ពិនិត្យឡើងវិញ គអសក ឆ្នាំ២០១០* នៅក្នុងផ្នែកនៃការរៀបចំសម្រាប់ពិនិត្យឡើងវិញ *គអស របស់សហប្រជាជាតិ ឆ្នាំ២០១០* ដែលនឹងប្រព្រឹត្តទៅនៅក្នុងខែកញ្ញា ឆ្នាំ២០១០ ។ ការវិភាគដំបូងបង្អស់ ដែលពិនិត្យពី វឌ្ឍនភាពនៃការសម្រេចចំណុចដៅនៃ*គអសក* បង្ហាញថា :

ក. រាជរដ្ឋាភិបាលកម្ពុជា នឹងឈានទៅសម្រេចចំណុចដៅនៃ *គអសក* នៅឆ្នាំ២០១៥ ចំពោះ គោលដៅ ទី៤ ទី៦ ទី៨ និងទី៩ ។

ខ. ទោះបីជាមានបញ្ហាប្រឈមថ្មីៗ ដែលបានលេចចេញ ដោយមិនបានរំពឹងទុកជាមុន ដោយសារវិបត្តិហិរញ្ញវត្ថុ និងឱនភាពសេដ្ឋកិច្ចសកលលោក ក៏ដោយ ក៏រាជរដ្ឋាភិបាលកម្ពុជានៅតែប្តេជ្ញាចិត្ត ការពារសមិទ្ធផលនានា ដែលសម្រេចបានដោយលំបាកកន្លងមក នៅក្នុងការកាត់បន្ថយភាពក្រីក្រ និងរក្សាលើគន្លងផ្លូវការងារ ឆ្ពោះទៅសម្រេចចំណុចដៅនានានៃ *គអសក* នៅឆ្នាំ២០១៥ ចំពោះ គោលដៅ ទី១ និង ទី២ ។

គ. ចាប់ផ្តើមចេញពីប្រទេសជាតិមួយ ដែលត្រូវបានបំផ្លិចផ្លាញទាំងស្រុងនូវ រចនាសម្ព័ន្ធអប់រំនិងសុខាភិបាល យើងបានខិតខំរែងឆ្ងាយមកហើយ ក្នុងការស្តារនិងកសាងឡើងវិញនូវសេវាអប់រំនិងសុខាភិបាលរបស់យើង ។ ទោះបីជាយើងសម្រេចបានវឌ្ឍនភាពដ៏ធំធេងកន្លងមកដូចនេះក៏ដោយ បើយើងពិនិត្យមើលពីទំហំនៃការងារ និងធនធានដែលមានកម្រិតសម្រាប់រយៈពេលខ្លីរបស់យើង ក៏ដូចជា ភាពមានកម្រិតនៃធនធានមនុស្ស ធ្វើឱ្យយើងមានលទ្ធភាពទាប ក្នុងការសម្រេចឱ្យបានចំណុចដៅមួយចំនួននៃ *គអសក* ដែលបានកំណត់សម្រាប់ឆ្នាំ២០១៥ គឺ គោលដៅ ទី២ ទី៥ និង ទី៧ ។

៧. ការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរៀបចំ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* គឺដើម្បីសម្រេចគោលដៅចម្បងពីរ ។ *គោលដៅទី១* គឺដើម្បីបន្សុំអាណត្តិកាលរបស់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ជាមួយអាណត្តិរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា សំដៅធានាថា សកម្មភាពដែលបានគ្រោងទុកទាំងឡាយរបស់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបានរៀបចំឡើង ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានកំណត់នៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* ។ *គោលដៅទី២* គឺ ដើម្បីធានាថា ការងារដែលត្រូវលើកឡើង ដោយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តគោល-នយោបាយអាទិភាពទាំងនេះ ត្រូវបានរៀបចំ ដោយមានការគិតគូរដល់ ផលប៉ះពាល់នៃការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក ដែលអាចមានមកលើសេដ្ឋកិច្ចកម្ពុជា ។

៨. ដើម្បីធ្វើឱ្យ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ក្លាយជាឧបករណ៍ឬផែនទីចង្អុលផ្លូវមួយ សម្រាប់ការអនុវត្តនូវបណ្តាគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានលើកឡើងនៅក្នុង *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២* វិធីសាស្ត្រនៃការធ្វើផែនការ ត្រូវបានកែលម្អបន្ថែមទៀត ។ វិធីសាស្ត្រនៃការកែលម្អនេះ បានផ្តោតលើ *តើក្រសួង-ស្ថាប័នណា* ជាអ្នកទទួលខុសត្រូវ ក្នុងការអនុវត្តគោលនយោបាយអាទិភាពទាំងឡាយ នៅក្នុងមុំនីមួយៗនៃ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ តើសកម្មភាពជាក់លាក់អ្វីខ្លះ* ដែលក្រសួង-ស្ថាប័នទទួលខុសត្រូវ បានគ្រោងឡើង ដើម្បីអនុវត្តគោលនយោបាយអាទិភាពទាំងឡាយ និង *តើតម្លៃប៉ុន្មាន* ដែល ក្រសួង-ស្ថាប័នទទួលខុសត្រូវ ត្រូវប៉ាន់ស្មានឱ្យបានត្រឹមត្រូវបំផុត ដើម្បីអនុវត្តសកម្មភាពទាំងឡាយ ដែល

បានគ្រោងសម្រាប់អំឡុងឆ្នាំ២០០៩-២០១៣ ។ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រូវបានរៀបចំឡើងផ្អែកលើធាតុចូលនានា ពីក្រសួង-ស្ថាប័ននីមួយៗរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ក្រសួងផែនការបានអនុវត្តវិធានការសំខាន់ៗ នានា ដើម្បីធានាថា គ្រប់ភាគីដែលមានចំណែកពាក់ព័ន្ធទាំងអស់ មានឱកាសក្នុងការផ្តល់ធាតុចូល និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ក្នុងការរៀបចំធាតុចូលរបស់ខ្លួនផ្ញើមកក្រសួងផែនការ ។

៩. រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំក្រុមការងារមួយ ដឹកនាំដោយក្រសួងផែនការ ដើម្បីដំណើរការពង្រឹងការធ្វើសុខដុមនីយកម្ម ការងារផែនការ ការចំណាយវិនិយោគសាធារណៈរបស់រដ្ឋ និង ការបែងចែកនិងប្រើប្រាស់ធនធានពីគ្រប់ប្រភព សម្រាប់អនុវត្តកម្មវិធីវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនេះ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ បានធ្វើការយ៉ាងជិតស្និទ្ធ ជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាថា ដំណើរការនៃការកំណត់គម្រោងវិនិយោគសាធារណៈ ដោយក្រសួង-ស្ថាប័ន មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹង ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកា សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

១០. ការបង្កើត *"សូចនាករនិងចំណុចដៅសំខាន់ៗសម្រាប់ការតាមដានត្រួតពិនិត្យ"* គឺជាផ្នែកមួយយ៉ាងសំខាន់នៃដំណើរការរៀបចំ *ផយអជ* សម្រាប់ធានាឱ្យការតាមដានត្រួតពិនិត្យ ការអនុវត្ត *ផយអជ បច្ចុប្បន្នកម្ម* ឱ្យមានប្រសិទ្ធភាព ។ ដើម្បីធានាការចូលរួម របស់អ្នកដែលមានចំណែកពាក់ព័ន្ធទាំងអស់ ក្រសួងផែនការបានបង្កើតឡើងនូវ *អនុក្រុមការងារនៃក្រុមការងារបច្ចេកទេសចម្រុះផែនការនិងកាត់បន្ថយភាពក្រីក្រ* ដើម្បីរៀបចំ *សូចនាករនិងចំណុចដៅសំខាន់ៗសម្រាប់ការតាមដានត្រួតពិនិត្យ* ដែលនឹងត្រូវធ្វើបច្ចុប្បន្នកម្ម សម្រាប់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដោយផ្តោតការយកចិត្តទុកដាក់លើ បទពិសោធន៍នានាដែលទទួលបាននៅក្នុងអំឡុងពេលនៃការតាមដានត្រួតពិនិត្យ *ផយអជ ២០០៦-២០១០* ហើយនឹងបញ្ចប់កិច្ចការនេះ នៅមុនពេលដែលការងារវិភាគវាយតម្លៃរួមលើកទី១ ស្តីពីវឌ្ឍនភាពនៃការអនុវត្ត *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ចាប់ផ្តើមដំណើរការ ។ អនុក្រុមការងារនេះ ត្រូវបានតម្រូវឱ្យធានាថា *សូចនាករនិងចំណុចដៅសំខាន់ៗសម្រាប់ការតាមដានត្រួតពិនិត្យ* របស់ *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ត្រូវបំពេញនូវលក្ខណៈវិនិច្ឆ័យសំខាន់ៗចំនួនពីរ គឺ : (១) សូចនាករនិងចំណុចដៅនីមួយៗដែលបានស្នើឡើង ត្រូវតែជាសូចនាករដែលអាចវាស់វែង ហើយត្រូវធានាថា ទិន្នន័យសម្រាប់ការតាមដានត្រួតពិនិត្យលើសូចនាករនិងចំណុចដៅទាំងនោះ អាចមានទាន់ពេលវេលាសម្រាប់ការប្រើប្រាស់ ឬក៏អាចប្រមូលបានតាមពេលកំណត់ (២) ក្រសួងឬស្ថាប័នមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបានកំណត់ ហើយបានយល់ព្រមធ្វើជាអ្នកទទួលខុសត្រូវក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ លើការវិវត្តប្រែប្រួល នៃសូចនាករនិងចំណុចដៅទាំងនោះ ។ *អនុក្រុមការងារនៃក្រុមការងារបច្ចេកទេសចម្រុះផែនការនិងកាត់បន្ថយភាពក្រីក្រ* បានខិតខំ

ប្រឹងប្រែងដើម្បីសម្រេចការងារនេះ ហើយក្រសួងផែនការក៏សូមថ្លែងអំណរគុណ ចំពោះការសម្រេចបានរបស់ក្រុមការងារនេះ ។ រហូតមកដល់ពេលនេះ *សូចនាករនិងចំណុចដៅសំខាន់ៗសម្រាប់ការតាមដានត្រួតពិនិត្យ ផយអជ ២០០៦-២០១០* នៅពុំមានការប្រែប្រួលឡើយ ។ ទោះជាដូចនេះក្តី *អនុក្រុមការងារនៃក្រុមការងារបច្ចេកទេសចម្រុះផែនការនិងកាត់បន្ថយភាពក្រីក្រ* កំពុងបន្តការងារនេះឱ្យបានចប់សព្វគ្រប់ នៅខែមិថុនា ឆ្នាំ២០១១ ដែលនេះគឺជាអាទិភាពខ្ពស់របស់ក្រសួងផែនការ ។

១១. រាជរដ្ឋាភិបាលកម្ពុជា បានកំណត់នូវចំណុចដៅនៃតម្រូវការវិនិយោគរបស់វិស័យសាធារណៈ ដែលអាចមានតម្លៃប្រមាណ *២៥ ៧៤០,៦ពាន់លានរៀល (ស្មើនឹង ៦,២៧៨ពាន់លានដុល្លារអាមេរិក)* ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់ខ្លួន សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ។ តម្លៃប៉ាន់ស្មាននេះ រួមបញ្ចូល នូវ :

- ៣២ភាគរយនៃការវិនិយោគដែលបានកំណត់ ត្រូវជា ៨ ២៣៧ពាន់លានរៀល (ស្មើនឹង ២,០០៩ពាន់លានដុល្លារអាមេរិក) សម្រាប់វិស័យសង្គមកិច្ច ។
- ២៤ភាគរយនៃការវិនិយោគដែលបានកំណត់ ត្រូវជា ៦ ១៧៧,៧ពាន់លានរៀល (ស្មើនឹង ១,៥០៧ពាន់លានដុល្លារអាមេរិក សម្រាប់វិស័យសេដ្ឋកិច្ច។
- ២១ភាគរយនៃការវិនិយោគដែលបានកំណត់ ត្រូវជា ៥ ៤០៥,៥ពាន់លានរៀល (ស្មើនឹង ១,៣១៨ពាន់លានដុល្លារអាមេរិក សម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធ។
- ២១ភាគរយនៃការវិនិយោគដែលបានកំណត់ ត្រូវជា ៥ ៤០៥,៥ពាន់លានរៀល (ស្មើនឹង ១,៣១៨ពាន់លានដុល្លារអាមេរិក សម្រាប់វិស័យសេវាកម្ម និងកម្មវិធីអន្តរវិស័យ ។

១២. ដោយផ្អែកលើក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម រាជរដ្ឋាភិបាលកម្ពុជាបានវិភាជថវិកាប្រមាណ ៤ ១២៦,៧ពាន់លានរៀល (ស្មើនឹង ជាង ១ពាន់លានដុល្លារអាមេរិក) ដើម្បីអនុវត្តបណ្តាគម្រោងអាទិភាពរបស់ខ្លួន នៅក្នុងនីតិកាលទី៤ នៃរដ្ឋសភា ។ រាជរដ្ឋាភិបាលកម្ពុជាមានជំនឿជឿជាក់ថា តម្រូវការវិនិយោគសម្រាប់វិស័យសាធារណៈ ដែលមានប្រមាណ *៤ ៣២១ពាន់លានរៀល (ស្មើនឹងជាង ១ពាន់លានដុល្លារអាមេរិក)* ក្នុងមួយឆ្នាំ អាចនឹងទទួលបាន ពីការបន្តគាំទ្រពីដៃគូអភិវឌ្ឍន៍ជាប្រពៃណីនិងមិនមែនប្រពៃណី និងពីចំណូលបន្ថែមថ្មីពី ប្រេង ឧស្ម័ន និងធនធានរ៉ែ នៅពេលដែលអាជីវកម្មនេះ ត្រូវបានដំណើរការជាលក្ខណៈពាណិជ្ជកម្ម ។

១៣. ចំពោះកាលានុវត្តភាពនិងបញ្ហាប្រឈមនានា ដែលចាំបាច់ត្រូវដោះស្រាយនៅក្នុងអំឡុងពេលនៃការអនុវត្ត *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ឯកសារ *ផយអជ បច្ចុប្បន្នកម្ម* ផ្តល់នូវការវិភាគស៊ីជម្រៅលើបញ្ហានេះ ។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជម្រាបជូន អង្គវេទិកាទាំងមូល ពី អនុសាសន៍របស់ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី នៅក្នុងពិធីបើកសន្និសីទ ស្តីពី ទស្សនវិស័យសម្រាប់កម្ពុជាឆ្នាំ២០០៩ លើប្រធានបទស្តីពី *"កម្ពុជា*

*និងវិបត្តិសេដ្ឋកិច្ចពិភពលោក : ផលប៉ះពាល់ គោលនយោបាយ ឆ្លើយតប និង វិធានការ*" ។ សម្តេចអគ្គសេនាបតី តេជោ នាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ថា "*បញ្ហាប្រឈមទាំងនេះ តម្រូវឱ្យមានមិនត្រឹមតែ កិច្ចសហប្រតិបត្តិការនិងជវភាពរវាង រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ប៉ុណ្ណោះទេ ថែមទាំងតម្រូវឱ្យមានការសម្របសម្រួលសហការនៅក្នុងចង្កោមស្ថាប័ន ក្រសួង មន្ទីរ របស់រាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អភិវឌ្ឍន៍ផងដែរ ។ នៅក្នុងវិស័យសំខាន់ៗ ដូចជា កសិកម្ម និងអភិវឌ្ឍន៍ជនបទ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងធារាសាស្ត្រ និងការគ្រប់គ្រងធនធានទឹក ព្រមទាំង ការសម្រួលពាណិជ្ជកម្ម ។ ខ្ញុំសូមឱ្យក្រសួងមន្ទីរពាក់ព័ន្ធទាំងអស់ ជាពិសេស ថ្នាក់ដឹកនាំក្រសួង ត្រូវធ្វើការជាមួយគ្នា និងសហការគ្នាឱ្យកាន់តែជិតស្និទ្ធ ថែមទៀត ដើម្បីធានាថា កម្មវិធីអភិវឌ្ឍន៍ ត្រូវបានរៀបចំឡើងនិងអនុវត្តដោយឆាប់រហ័ស និងមានប្រសិទ្ធភាព ។ ការធ្វើបែបនេះធនធានហិរញ្ញប្បទាន ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍របស់យើង នឹងត្រូវបានឱ្យផ្តល់កាន់តែលឿន សម្រាប់ការអភិវឌ្ឍគម្រោងការរបស់ខ្លួន ។ ការងារទាំងនេះ មិនមែនងាយស្រួលអនុវត្តទេ ប៉ុន្តែ ដោយសារវិបត្តិនេះតម្រូវឱ្យយើងទាំងអស់គ្នាត្រូវ ធ្វើការរួមគ្នាកាន់តែច្រើនថែមទៀត ដើម្បីដោះស្រាយបញ្ហាប្រឈម*" ។

១៤. ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ ការពង្រឹងសមត្ថភាពរបស់ស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្តល់សេវាកម្មរបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងដើម្បីជំរុញវប្បធម៌តម្លាភាពនិងគណនេយ្យភាព គឺជាការងារបន្ទាន់ចំពោះមុខ ។ ទន្ទឹមនឹងនេះ ការងារដែលត្រូវយកចិត្តទុកដាក់ដោះស្រាយចំពោះមុខ ផងដែរនោះ គឺត្រូវ :

- ការធានាឱ្យមាន ការផ្ទេរសុទ្ធសាធនូវធានធានសហប្រតិបត្តិការអភិវឌ្ឍន៍ កាន់តែច្រើនឡើង ដែលផ្តោតលើក្រុមជនងាយរងគ្រោះ និងប្រជាជនក្រីក្រនៅសហគមន៍ជនបទ ជាពិសេស សហគមន៍ជនបទដាច់ស្រយាល ។
- ការបង្កើនឱ្យបានច្រើន នូវសមាមាត្រនៃធនធានសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលបានធ្វើវិភាជ និងផ្តល់ដល់ក្រុមជនងាយរងគ្រោះនិងប្រជាជនក្រីក្រ តាមរយៈ វិធីសាស្ត្រនៃការផ្តល់កម្មវិធី ដែលផ្អែកលើ ការចូលរួមយ៉ាងសកម្មនៃប្រជាជនក្រីក្រក្នុងការប្រើប្រាស់នូវធនធានទាំងនេះ ដើម្បី លើកកម្ពស់ជីវភាពរស់នៅ និងបង្កើនប្រាក់ចំណូលរបស់ប្រជាជន និង ការរួមចំណែករបស់ពួកគាត់ទៅក្នុងសេដ្ឋកិច្ចជាតិ ។
- ការបោះជំហានយ៉ាងលឿនឆ្ពោះទៅរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងទូទាំងវិស័យ និងកម្មវិធីគាំទ្រទូទាំងវិស័យ ដើម្បីអនុវត្តយុទ្ធសាស្ត្រទាំងនោះ ដោយក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការគាំទ្រពីដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ ។

១៥. ខ្ញុំសូមធានាថា នៅពេលដែលយើងនៅតែប្តេជ្ញាចិត្តក្នុងការទទួលខុសត្រូវយ៉ាងពេញលេញ ក្នុងដំណើរការនៃការអភិវឌ្ឍរបស់យើង រាជរដ្ឋាភិបាលកម្ពុជា/ក្រសួងផែនការ ក៏នៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការបន្តដំណើរការអនុវត្តនូវវិធីសាស្ត្រដែលមានការចូលរួម នៅក្នុងដំណើរការនៃការរៀបចំ *ផយអជ* ក៏ដូចជា នៅក្នុងដំណើរការ

តាមដានត្រួតពិនិត្យ ការអនុវត្ត*ផយអជ* ។ ដូចយើងបានបោះជំហានមួយជំហានរួចហើយ ក្រសួងផែនការ ក៏បានប្តេជ្ញាចិត្ត ដោះស្រាយនូវបញ្ហាសំខាន់ៗមួយចំនួន ដែលពាក់ព័ន្ធនឹងការងារដែលត្រូវយកមកអនុវត្ត ដើម្បី :

- ពង្រឹងទំនាក់ទំនង រវាង ដំណើរការរៀបចំផែនការនិងការរៀបចំកម្មវិធីវិនិយោគសាធារណៈ ដែលរៀបចំឡើងដោយក្រសួងផែនការ ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រថវិកាសម្រាប់ក្រសួង-ស្ថាប័ន ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ការកៀរគរធនធានក្រៅប្រទេស ដោយគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- រៀបចំ និងអនុវត្តវិធីសាស្ត្រនានា ដែលនឹងពង្រឹង ទំនាក់ទំនងរវាង ផែនការជាតិ និងផែនការនៅថ្នាក់ក្រោមជាតិ ព្រមទាំងជាមួយនឹង ការផ្តួចផ្តើមនានារបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងក្របខ័ណ្ឌនៃកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ។

១៦. ជាទីបញ្ចប់ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា/ក្រសួងផែនការ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា វេទិកានេះនឹងធ្វើឱ្យធនធានសហប្រតិបត្តិការអភិវឌ្ឍន៍ ត្រូវបានយកទៅប្រើប្រាស់ សម្រាប់ការអនុវត្តសកម្មភាពអាទិភាពនានា ដែលបានកំណត់នៅក្នុង *ផយអជ បច្ចុប្បន្នកម្ម ២០០៩-២០១៣* ដើម្បីជាប្រយោជន៍ដល់ការអភិវឌ្ឍ សង្គម-សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ នៅកម្ពុជា ។

**សូមអរគុណ !**